# ចូលរួមសំអាតបរិស្ថាននៅក្នុងទីក្រុងភ្នំពេញដើម្បីទាំងអស់គ្នា !



ទន្ទឹមនឹងការរីកចម្រើននៃវិស័យសេដ្ឋកិច្ច ក្នុងនោះទីក្រុងភ្នំពេញក៏មានការកើនឡើងនៃសំរាមផងដែរ។ បញ្ហាចំបងនោះគឺការបោះបោលសំរាមនៅតាមផ្លូវ និងទីសាធារណៈនានាដែលវាជាកត្តាមួយធ្វើឲ្យមានការស្ទះប្រព័ន្ធលូបង្ហូរទឹក ជាហេតុនាំឲ្យមានការជន់លេចទីក្រុង និងបង្កជាមេរោគនៅក្នុងទឹក។ ដើម្បីចូលរួមចំណែកក្នុងការដោះស្រាយបញ្ហានេះទីភ្នាក់ងារ JICA បានរៀបចំកម្មវិធី ECO-City Project ឬហៅថា គម្រោងទីក្រុងអេកូ ដោយបានបង្កើតវីដេអូតុក្កតាដែលពន្យល់អំពីបញ្ហាសំរាម ព្រមទាំងដាក់បញ្ចូលរូបភាពដែលក្មេងៗបានគូរឲ្យមានចលនាក្នុងគោលបំណងធ្វើការបង្ហាញ និងអប់រំអំពីបរិស្ថាននៅជុំវិញខ្លួនយើង។



ក្នុងកម្មវិធីនេះផងដែរ ក៏មានសកម្មភាពប្រមូលសំរាម ដែលសំរាមប្រមាណជាង១០០ថង់ត្រូវបានប្រមូលដោយអ្នកចូលរួម។

ផ្តើមចេញពីយើងទាំងអស់គ្នា ពីពេលនេះតទៅដើម្បីធ្វើឲ្យទីក្រុងភ្នំពេញក្លាយជាទីក្រុងកាន់តែស្រស់ស្អាត !



សូមទស្សនាវីដេអូទាក់ទងនិងគម្រោងទីក្រុងអេកូតាមរយៈ

YouTube ដោយវាយពាក្យថា "ECO City Project គម្រោងទីក្រុងអេកូ"